# សុសុមារជាតក



ព្រះសាស្តាកាលស្តេចគង់នៅវត្តជេតពន ទ្រង់ប្រារព្ធការព្យាយាមសម្លាប់ (ព្រះអង្គ) របស់ភិក្ខុទេវទត្ត បានត្រាស់ព្រះធម្មទេសនានេះ មានពាក្យថា **អលំ មេតេហិ អម្ពេហិ** ដូច្នេះជាដើម ។

គ្រានោះ ព្រះសាស្តាស្តាប់ថា ទេវទត្តព្យាយាមដើម្បីសម្លាប់ (ព្រះអង្គ) ដូច្នេះហើយ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះទេ ដែលទេវទត្តព្យាយាមសម្លាប់តថាគតនោះ សូម្បីក្នុងកាលមុន ក៏ព្យាយាម (សម្លាប់តថាគតដែរ) តែមិនអាចធ្វើសូម្បីត្រឹមតែសេចក្តីតក់ស្លុត (ដល់តថាគតបានឡើយ) ដូច្នេះហើយ ទ្រង់នាំអតីតនិទានមកថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងកំណើតស្វា ក្នុងហិមវន្តប្រទេស លោកជាសត្វដល់ព្រមដោយកម្លាំង ដូច

*ជាដំរី មានសរីរៈធំ ជាសត្វមានភាពល្អដ៏លើស សម្រេចការនៅក្នុងដងព្រៃ ត្រង់ទន្លេគង្គាបត់ ។ ពេលនោះ មានក្រពើឈ្មោលមួយរស់នៅក្នុងទន្លេគង្គា ។*

*ភរិយារបស់ក្រពើនោះ ឃើញសរីរៈរបស់ព្រះពោធិសត្វហើយ កើតចំណង់ប្លែកក្នុងសាច់បេះដូងរបស់ព្រះពោធិសត្វ ទើបពោលនឹងក្រពើឈ្មោលថា បពិត្រស្វាមី ខ្ញុំមានចំណង់ចង់ស៊ីសាច់បេះដូងស្តេចស្វានោះ។*

***ក្រពើឈ្មោលពោលថា*** *នែនាង យើងជាសត្វត្រាច់ទៅក្នុងទឹក ស្វានោះជាសត្វត្រាច់ទៅលើគោក យើងនឹងចាប់ស្វានោះ ដូចម្តេច ?*

***ក្រពើញីពោលថា*** *អ្នកចូរចាប់ស្វានោះដោយឧបាយយ៉ាងណាមួយចុះ បើខ្ញុំមិនបានស៊ីសាច់បេះដូងស្វានោះទេ ខ្ញុំនឹងស្លាប់ ។*

***ក្រពើឈ្មោលពោលលួងលោមក្រពើញីថា*** *បើយ៉ាងនោះ នាងកុំសោយសោកឡើយ យើងមានឧបាយមួយ នឹងអាចឲ្យនាងបានស៊ីសាច់បេះដូចស្វានោះ ។*

*ក្រពើឈ្មោលក៏ទៅកាន់សម្នាក់ព្រះពោធិសត្វ ដែលចូលមក អង្គុយផឹកទឹកទន្លេគង្គា ហើយពោលយ៉ាងនេះថា នែវានរិន្ទ ក្នុងប្រទេសនេះ អ្នកបរិភោគផ្លែឈើចត់ ហើយត្រាច់ទៅក្នុងទីដែលធ្លាប់ទៅតែម្យ៉ាង ធ្វើអ្វី ? នៅនឹងច្រាំងទន្លេគង្គា (ឯណោះ) មានផ្លែឈើដែលមានរសផ្អែម ច្រើន គឺផ្លែស្វាយ ផ្លែខ្នុរសម្ងជាដើម មិនមានទីបំផុត អ្នកទៅទីនោះ នឹងបានបរិភោគផលាផល រមែងមិនគួរឬ ?*

***ព្រះមហាសត្វពោលថា*** *នែស្តេចក្រពើ ទន្លេគង្គានេះ មានទឹកច្រើន ហើយធំណាស់ យើងនឹងទៅក្នុងទីនោះ ដូចម្តេច ?*

***ក្រពើពោលថា*** *បើអ្នកចង់ទៅ យើងឲ្យអ្នកឡើងជិះលើខ្នងរបស់យើង ហើយនាំអ្នកទៅ ។*

***ព្រះពោធិសត្វជឿក្រពើ ហើយទទួលថា*** *ល្អ ។*

***កាលក្រពើពោលថា*** *បើយ៉ាងនោះ អ្នកចូរមក ឡើងលើជិះខ្នងខ្ញុំចុះ ។*

*ព្រះពោធិសត្វក៏ឡើងជិះក្រពើនោះទៅ ក្រពើនាំទៅបានបន្តិច ក៏ញ៉ាំងព្រះពោធិសត្វឲ្យលិចចុះក្នុងទឹក ។*

***ព្រះពោធិសត្វពោលថា*** *នែសម្លាញ់ អ្នកចាប់ខ្ញុំជ្រមុជទឹកនេះ ព្រោះមានរឿងអ្វី ?*

***ក្រពើពោលថា*** *យើងមិនមែនចាប់អ្នកទៅតាមធម្មតាទេ ភរិយារបស់យើងកើតចំណង់ប្លែកក្នុងសាច់បេះដូងរបស់អ្នក នាងចង់ស៊ីសាច់បេះដូងអ្នក ។*

***ព្រះមហាសត្វពោលថា*** *នែសម្លាញ់ អ្នកនិយាយនិងធ្វើនេះ ល្អហើយ បើសិនជាបេះដូងមានក្នុងពោះយើង កាលយើងត្រាច់ទៅលើចុងមែកឈើ បេះដូងយើងនឹងគប្បីបែកជាចំណែកតូចៗ ។*

***ក្រពើសួរថា*** *ចុះអ្នកទុកបេះដូងនៅទីណា ?*

*ព្រះពោធិសត្វឃើញដើមល្វាមួយ ដែលមានផ្លែទុំជាចង្កោមៗ ក្នុងទីជិតនោះ រួចក៏ពោលថា អ្នកចូរមើលបេះដូងទាំងឡាយរបស់ខ្ញុំព្យួរនឹងដើមល្វានោះ ។*

***ក្រពើពោលថា*** *ប្រសិនបើអ្នកឲ្យបេះដូងដល់ខ្ញុំ ខ្ញុំនឹងមិនសម្លាប់អ្នក ។*

***ព្រះពោធិសត្វពោលថា*** *បើយ៉ាងនោះ អ្នកចូរនាំខ្ញុំទៅកាន់ទីនោះ ខ្ញុំនឹងឲ្យបេះដូងដែលព្យួរនឹងដើមល្វាដល់អ្នក ។*

*ក្រពើក៏នាំព្រះពោធិសត្វទៅកាន់ទីនោះ ។*

*ព្រះពោធិសត្វលោតចេញពីខ្នងក្រពើ ទៅអង្គុយលើដើមល្វា ហើយពោលថា នៃក្រពើល្ងង់សម្ងាញ់ អ្នកសម្គាល់ថា បេះដូងសត្វទាំងឡាយនៅនឹងចុងឈើឬ អ្នកជាបុគ្គលល្ងង់ យើងបោកបញ្ឆោតអ្នកទេតើ ផលាផលរបស់អ្នក ចូរជារបស់អ្នកចុះ អ្នកមានតែសរីរៈធំ តែមិនមានបញ្ញា ដូច្នេះកាលប្រកាសសេចក្តីនោះ ទើបពោលគាថាទាំងឡាយនេះថា*

អលំ មេតេហិ អម្ពេហិ, ជម្ពូហិ បនសេហិ ច;
យានិ ចារំ សមុទ្ទស្ស, វរំ មយ្ហំ ឧទុម្ពរោ។

*ផ្លែឈើទាំងឡាយណា (ដែលអ្នកឃើញហើយ) នាត្រើយសមុទ្រខាងនាយ ផ្លែឈើទាំងនោះ គឺផ្លែស្វាយក្តី ផ្លែព្រីងក្តី ផ្លែខ្នុរក្តី មិនគួរដល់យើងឡើយ ដើមល្វា (នេះឯង) ជាឈើដ៏ប្រសើររបស់យើង ។*

មហតី វត តេ ពោន្ទិ, ន ច បញ្ញា តទូបិកា;
សុសុមារ វញ្ចិតោ មេសិ, គច្ឆ ទានិ យថាសុខំ។

*សរីរៈរបស់អ្នកធំមែន ប៉ុន្តែប្រាជ្ញាសមគួរនឹងសរីរៈនោះមិនមាន នៃក្រពើ ឯងត្រូវអញបញ្ឆោតហើយ ឥឡូវចូរឯងទៅតាមស្រួលចុះ ។*

*ព្រះសាស្តានាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា*

**តទា សុសុមារោ ទេវទត្តោ អហោសិ** *ក្រពើឈ្មោលក្នុងកាលនោះ បានមកជាទេវទត្ត*

**សុសុមារី ចិញ្ចមាណវិកា** *ក្រពើញីបានមកជានាងចិញ្ចមាណវិកា*

**កបិរាជា បន អហមេវ អហោសឹ** *ចំណែកស្តេចស្វា គឺ តថាគតនេះឯង ។*

*សុសុមារជាតក ចប់ ៕*

*(ជាតកដ្ឋកថា សុត្តន្តបិកដ ខុទ្ទកនិកាយ ជាតក ទុកនិបាត នតំទឡ្ហវគ្គ បិដកលេខ ៥៨ ទំព័រ ១០៦)*

*ដោយស.ដ.រ.ថ.*